## តើត្រូវធ្វើដូចម្តេចដើម្បីក្លាយជាអ្នករៀនសូត្រប្រកបដោយប្រសិទ្ធភាព?

*រៀបរៀងដោយ ឡេងឆាយ*

មុនពេលអ្នកអាចរៀនប្រធានបទណាមួយឬជំនាញណាមួយមានប្រសិទ្ធភាព អ្នកត្រូវយល់ដឹងអំពីវិធីដែលអ្នកជ្រើសយកដើម្បីរៀនសូត្រពីវា។អ្នកអាចក្លាយជាអ្នករៀនសូត្រប្រកបដោយប្រសិទ្ធភាពម្នាក់ តាមរយៈការប៉ាន់ប្រមាណបែបបទរៀនសូត្ររបស់អ្នកផ្ទាល់ ហើយកំនត់យក និងប្រើប្រាស់វិធីសមស្របបំផុត អំពីថាតើត្រូវរៀនសូត្រដោយវិធីណា។

### ជំនាញរៀនសូត្រសំខាន់ៗដែលអាចជួយអ្នកអោយក្លាយជាអ្នករៀនសូត្រប្រកបដោយប្រសិទ្ធភាពបានរួមមាន៖

- ការធ្វើកំនត់ត្រាផ្ទាល់ខ្លួន
- ស្ទឹងជីវិត ឬទន្លេជីវិត
- វដ្តរៀនសូត្រពីសកម្មភាព
- ការសង្កេតបែបវិជ្ជមាន
- រឿងរ៉ាវផ្លាស់ប្តូរ
- ផែនទីគំនិត
- ជំនាញគិតបែបវិភាគ/ស៊ីជំរៅ
- ជំនាញបង្កើត និងសួរសំនួរ
- ជំនាញស្តាប់សកម្ម
- ជំនាញនៃការអាន
- ជំនាញសង្កេត

មានឥរិយាបថចំនួន៦ ដែលគួរប្រកាន់យក ដើម្បីក្លាយជាអ្នករៀនសូត្រប្រកបដោយជោគជ័យ៖

**១.ការចង់ចេះចង់ដឹង**

ខ្ញុំព្យាយាមរកចំលើយដោយខ្លួនឯង ជាជាងរង់ចាំគេប្រាប់។

**២.មានទំនុកចិត្ត**

ខ្ញុំពង្រឹងបន្ថែមលើចំនុចខ្លាំង និងព្យាយាមបំបាត់ចំនុចខ្សោយរបស់ខ្ញុំ។

**៣.មានការប្តេជ្ញាចិត្ត**

ប្រើប្រាស់ពេលវេលា និងថាមពលដើម្បីរៀនសូត្រ ហើយសំរេចគោលដៅរបស់ខ្ញុំមួយជំហានម្តងៗ។

**៤.ការផ្តោតអារម្មណ៍**

ផ្តោតលើការងារបច្ចុប្បន្ន ហើយព្យាយាមបំបាត់នូវការរំខាននានា។

**៥.មានជំនឿចិត្តខ្ពស់**

ខ្ញុំប្រាកដជាអាចធ្វើវាបាន។

**៦.មានការសរសើរខ្លួនឯង**

អបអរសាទរចំពោះជោគជ័យតូចៗរបស់ខ្ញុំ និងជោគជ័យធំៗ។


This learning article shared by Cambodian Learning Facilitators (www.camlefa.org).
This article can be copied, reproduced and used for any capacity development purpose, but source need to be clearly indicated.